ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិ**
**គ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា**

លេខ : ០៧៣ សលទ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារដឹកនាំសិក្សានិងរៀបចំអភិវឌ្ឍផ្លូវជិះកង់ទេសចរណ៍ ស្របតាមបណ្តោយឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៦៧១ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៤ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ១៧១ អនក្រ.បក ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋាន ចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៧៣ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋាន ចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ២៨៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិសំណង់
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តព្រះសីហនុ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីគម្រោងអភិវឌ្ឍក្រុងបូកគោ
- យោងសារាចរណែនាំលេខ០១ សរណន ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា
- យោងសេចក្តីសម្រេចលេខ១៣១ សសរ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រ
- យោងសេចក្តីសម្រេចលេខ០០១ សសរ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងកែប
- យោងសេចក្តីសម្រេចលេខ០០៣ សសរ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងកំពត
- យោងសេចក្តីសម្រេចលេខ០៧៦ សសរ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងខេមរភូមិន្ទ
- យោងសេចក្តីសម្រេចលេខ០៤៥ សសរ ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ
- យោងសេចក្តីសម្រេចលេខ០៨១សសរ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣ ស្តីពីការប្រគល់ភារកិច្ចជូនថ្នាក់ដឹកនាំក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងលិខិតលេខ១៤៩សជណ.ដប ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា

## សម្រេច

**ប្រការ១._**

បង្កើតក្រុមការងារដឹកនាំសិក្សានិងរៀបចំអភិវឌ្ឍផ្លូវជិះកង់ទេសចរណ៍ស្របតាមបណ្តោយឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាព៖

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត **ម៉ែន សុផល** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា(គ.អ.ឆ.ក.) | ប្រធាន |
| ២. ឯកឧត្តម **នី ផល្លី** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ និងជាអគ្គលេខាធិការរង គ.អ.ឆ.ក. | អនុប្រធាន |
| ៣. ឯកឧត្តម **លី ស្មើ** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៤. ឯកឧត្តម **យស់ ឆោមណារ៉ាឌី** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៥. ឯកឧត្តម **ហាឌ្យ សុគតសំភារ** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា | អនុប្រធាន |
| ៦. ឯកឧត្តម **អ៊ាន់ មុនីនាថ** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាអគ្គលេខាធិការរង គ.អ.ឆ.ក. | អនុប្រធាន |
| ៧. ឯកឧត្តម **គីម ឈុង** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាអគ្គលេខាធិការរង គ.អ.ឆ.ក. | អនុប្រធាន |
| ៨. ឯកឧត្តម **មាន ច័ន្ទអ៊ាន់នី** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាអគ្គលេខាធិការរង គ.អ.ឆ.ក. | សមាជិក |
| ៩. ឯកឧត្តម **កើត សារ៉េត** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១០. ឯកឧត្តម **មែន វ័ន្ត** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១១. ឯកឧត្តម **ហ៊ុន កុសល** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១២. ឯកឧត្តម **សូ សិទ្ធា** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៣. ឯកឧត្តម **វ័ន្ត ពិសិដ្ឋ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម និងជាអគ្គលេខាធិការរង គ.អ.ឆ.ក. | សមាជិក |
| ១៤. ឯកឧត្តម **ម៉ុង សុខលាភ** | ប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច និងជាអគ្គលេខាធិការរង គ.អ.ឆ.ក. | សមាជិក |

| | | |
|---|---|---|
| ១៥. ឯកឧត្តម **ហ៊ី ចិន្តា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានលំនៅឋាន និងជាអគ្គលេខាធិការរង គ.ជ.ន.ជ. | សមាជិក |
| ១៦. ឯកឧត្តម **ថៃ ចន្ថា** | អគ្គលេខាធិការរង គ.អ.ធ.ក. | សមាជិក |
| ១៧. ឯកឧត្តម **ម៉ៅ គ្រឹង** | អគ្គលេខាធិការរង គ.អ.ធ.ក. | សមាជិក |
| ១៨. ឯកឧត្តម **ខ្វិច សុធ្ធារិទ្ធិ** | អគ្គលេខាធិការរង គ.អ.ធ.ក. | សមាជិក |
| ១៩. លោក **ស៊ុំ មនោរម្យ** | នាយករងខុទ្ទកាល័យ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២០. កញ្ញា **អ៊ុំ ភណ្ឌារា** | ជំនួយការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិកា |
| ២១. លោក **ជុំ ប៊ុរី** | ជំនួយការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២២. លោក **ម៉ិល តិរ៉ៃរត្ន** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |

២៣. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកែប សមាជិក

២៤. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត សមាជិក

២៥. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ សមាជិក

២៦. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកោះកុង សមាជិក។

ក្រុមការងារដឹកនាំសិក្សានិងរៀបចំអភិវឌ្ឍផ្លូវជិះកង់ទេសចរណ៍ស្របតាមបណ្ដោយឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា មានភារកិច្ចៈ

- រៀបចំសិក្សាខ្សែផ្លូវនិងនិយាមកាគម្រោងអភិវឌ្ឍផ្លូវជិះកង់ទេសចរណ៍
- សិក្សាគម្រោងប្លង់ស្ថាបត្យកម្មផ្លូវជិះកង់ទេសចរណ៍
- សិក្សាគម្រោងប្លង់វិស្វកម្មផ្លូវជិះកង់ទេសចរណ៍
- សហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងអាជ្ញាធរមូលដ្ឋាន ដើម្បីសិក្សានិងប្រមូលទិន្នន័យ សម្រាប់បម្រើដល់ការងារអភិវឌ្ឍផ្លូវជិះកង់ទេសចរណ៍
- ដឹកនាំពិគ្រោះយោបល់និងសម្របសម្រួលជាមួយរដ្ឋបាលខេត្ត មន្ទីរនិងអង្គភាព រដ្ឋបាលក្រុង ស្រុក អាជ្ញាធរមូលដ្ឋាន និងផ្នែកឯកជនពាក់ព័ន្ធ ក្នុងការអភិវឌ្ឍផ្លូវជិះកង់ទេសចរណ៍
- រៀបចំឯកសារស្របតាមនីតិវិធី ដើម្បីស្នើសុំការសម្រេចគម្រោងអភិវឌ្ឍផ្លូវជិះកង់ទេសចរណ៍
- ត្រួតពិនិត្យ តាមដាន និងណែនាំ ក្នុងការអនុវត្តគម្រោងអភិវឌ្ឍផ្លូវជិះកង់ទេសចរណ៍
- លើកផែនការសកម្មភាពនិងគម្រោងថវិកា សម្រាប់ការអនុវត្តគម្រោងអភិវឌ្ឍផ្លូវជិះកង់ទេសចរណ៍
- ផ្ញើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ ជូន គ.អ.ធ.ក.អំពីលទ្ធផលនៃសកម្មភាពការងារ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីថ្នាក់ដឹកនាំ។

**ប្រការ២.**_

ក្រុមការងារដឹកនាំសិក្សានិងរៀបចំអភិវឌ្ឍផ្លូវជិះកង់ទេសចរណ៍ស្របតាមបណ្តោយឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា មានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានសមាសភាពៈ

| | | |
|---|---|---|
| ១. ឯកឧត្តម **រ័ត្ន ពិសិដ្ឋ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិង នគរូបនីយកម្ម និងជាអគ្គលេខាធិការរង គ.អ.ធ.ក. | ប្រធាន |
| ២. ឯកឧត្តម **ខិន សុទ្ធារិទ្ធិ** | អគ្គលេខាធិការរង គ.អ.ធ.ក. | អនុប្រធាន |
| ៣. លោក **វ៉ឹយ ទ៉ា** | ប្រធានផ្នែករៀបចំដែនដីនិងនគរូបនីយកម្ម | សមាជិក |
| ៤. លោក **មាស រិទ្ធី** | ប្រធានផ្នែកគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិ | សមាជិក |
| ៥. លោក **ម៉ុំ មុនីល** | ប្រធានផ្នែកគ្រប់គ្រងនិងអភិវឌ្ឍទេសចរណ៍ | សមាជិក |
| ៦. លោក **ចាប់ ច័ន្ទថេរា** | ប្រធានផ្នែកអប់រំ បណ្តុះបណ្តាល ផ្សព្វផ្សាយ និងព័ត៌មានវិទ្យា | សមាជិក |
| ៧. លោក **សុគន្ធ ឈារ៉ុង** | ប្រធានផ្នែកទំនាក់ទំនងសាធារណៈនិង សហប្រតិបត្តិការ | សមាជិក |
| ៨. លោក **អាន ចាន់ធឿន** | ប្រធានផ្នែកនីតិកម្មនិងដោះស្រាយវិវាទ | សមាជិក |
| ៩. លោក **ឱុយឡាយ មុទ្ធី** | អនុប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញកិច្ច | សមាជិក |
| ១០. លោក **ផល សុភ័ណ** | អនុប្រធាននាយកដ្ឋាននៃមន្ទីរពិសោធន៍ជាតិ សំណង់ | សមាជិក |
| ១១. លោក **ហេង សុខសំបូរ** | អនុប្រធានផ្នែកនៃអគ្គលេខាធិការដ្ឋាន គ.អ.ធ.ក. | សមាជិក |
| ១២. លោក **លី សុវណ្ណា** | អនុប្រធានផ្នែកនៃអគ្គលេខាធិការដ្ឋាន គ.ជ.ន.ជ. | សមាជិក |
| ១៣. លោក **ភួន សុនិត** | អនុប្រធានផ្នែករៀបចំដែនដីនិងនគរូបនីយកម្ម | សមាជិក |
| ១៤. លោក **ទី ពិសិដ្ឋ** | អនុប្រធានផ្នែករៀបចំដែនដីនិងនគរូបនីយកម្ម | សមាជិក |
| ១៥. លោក **ផូរ ច័ន្ទកក្តី** | អនុប្រធាននាយកដ្ឋាននៃមន្ទីរពិសោធន៍ជាតិ សំណង់ | សមាជិក |
| ១៦. លោក **នឹម នាង** | មន្ត្រីនៃនាយកដ្ឋានសំណង់ | សមាជិក |
| ១៧. លោក **សាំង មុតា** | មន្ត្រីជាប់កិច្ចសន្យា | សមាជិក |
| ១៨. លោក **សារិន សមរៈ** | អ្នកស្ម័គ្រចិត្តនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(អ្នករៀបចំដែនដី) | សមាជិក |
| ១៩. កញ្ញា **សុខុម ភិចឹម** | អ្នកស្ម័គ្រចិត្តនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(អ្នករៀបចំដែនដី) | សមាជិកា |
| ២០. កញ្ញា **ឈួន ច័ន្ទម៉ារីណែត** | អ្នកស្ម័គ្រចិត្តនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(អ្នករៀបចំដែនដី) | សមាជិកា |
| ២១. កញ្ញា **តុល សុខពិសី** | អ្នកស្ម័គ្រចិត្តនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់( ស្ថាបត្យករ) | សមាជិកា |
| ២២. កញ្ញា **ខិង កែវបញ្ញាបារមី** | អ្នកស្ម័គ្រចិត្តនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់( ស្ថាបត្យករ) | សមាជិកា |

២៣. លោក **ស៊ឹម សុវណ្ណណារ៉ា** អ្នកស្ម័គ្រចិត្តនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(ស្ថាបត្យករ) សមាជិក

២៤. លោក **ពុក សាក់គីនីន** អ្នកស្ម័គ្រចិត្តនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(ស្ថាបត្យករ)។ សមាជិក

លេខាធិការដ្ឋាននៃក្រុមការងារដឹកនាំសិក្សានិងរៀបចំអភិវឌ្ឍផ្លូវជិះកង់ទេសចរណ៍ស្របតាមបណ្តោយឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា មានភារកិច្ចបំពេញរាល់ការងារបច្ចេកទេសតាមការប្រគល់ជូនពីក្រុមការងារដឹកនាំសិក្សានិងរៀបចំអភិវឌ្ឍផ្លូវជិះកង់ទេសចរណ៍ស្របតាមបណ្តោយឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.**_

សមាសភាពនៃក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ។ ក្នុងករណីអវត្តមានប្រធានក្រុមការងារអាចចាត់តាំងអនុប្រធាន១(មួយ)រូប ឱ្យដឹកនាំកិច្ចប្រជុំជំនួស។

ប្រធានក្រុមការងារអាចអញ្ជើញថ្នាក់ដឹកនាំ ទីប្រឹក្សាក្រសួង ជំនួយការក្រសួង មន្ត្រីជំនាញ អ្នកហាត់ការ និងអ្នកស្ម័គ្រចិត្តផ្សេងទៀត របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឱ្យចូលរួមប្រជុំនិងបំពេញការងារតាមការចាំបាច់។

សមាសភាពនៃក្រុមការងារអាចប្រើមន្ត្រីជំនាញក្រោមឱវាទរបស់ខ្លួនឱ្យជួយការងារតាមការចាំបាច់។

រាល់ការចំណាយសម្រាប់ការបំពេញការងារ ត្រូវប្រើកញ្ចប់ថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬប្រភពផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រី។

**ប្រការ៤.**_

នាយកខុទ្ទកាល័យ គ្រប់អគ្គលេខាធិការ គ្រប់អគ្គនាយក អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកែប អភិបាលនៃគណៈអភិបាលខេត្តកំពត អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ អភិបាលនៃគណៈអភិបាលខេត្តកោះកុង សហគមន៍ និងឯកជនពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានរាយនាមក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែ ភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា**

**ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- សមាសភាព គ.អ.ឆ.ក.
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តកែប
- រដ្ឋបាលខេត្តកំពត
- រដ្ឋបាលខេត្តព្រះសីហនុ
- រដ្ឋបាលខេត្តកោះកុង
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ